ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ : ០៥៧សលាន គ.ជ.អ.ប

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន ដែលប្តេជ្ញាសម្រេចឱ្យបាននៅឆ្នាំ២០១៥។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ទាមទារឱ្យមានការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងពីគ្រប់អ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីរួមចំណែកក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងដៃគូអភិវឌ្ឍន៍នានាបានវិភាជន៍មូលនិធិទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់។

ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការអនុវត្តមុខងារខាងលើនេះ គ.ជ.អ.ប សូមធ្វើការណែនាំដូចខាងក្រោម :

## ១. គោលបំណងនៃការវិភាជន៍មូលនិធិ

ការផ្តល់មូលនិធិសម្រាប់អនុវត្តមុខងាររបស់ គ.ក.ន.ក មានគោលបំណង ដើម្បី :

- **លើកកម្ពស់សុខភាពមាតា** : បង្កើនការយល់ដឹងពីបញ្ហាសុខភាពមាតានិងទារក និងជួយស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេឱ្យទទួលបាននូវការថែទាំសុខភាព និងការសម្រាលកូនប្រកបដោយសុវត្ថិភាពនៅមណ្ឌលសុខភាព
- **បង្កើនការចូលរៀនរបស់កុមារអាយុ៣-៥ឆ្នាំ នៅមត្តេយ្យសិក្សាសហគមន៍ក្នុងឃុំ សង្កាត់** : ពង្រីកការផ្តល់សេវាគាំពារ និងការអភិវឌ្ឍកុមារតូចនៅឃុំ សង្កាត់ តាមរយៈការហាត់រៀនរបស់កុមារតូចនៅមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍

- **លើកកម្ពស់អនាម័យមូលដ្ឋាន** : ជួយឱ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់មានការយល់ដឹង និងប្រតិបត្តិទម្លាប់អនាម័យផ្ទាល់ខ្លួន និងអនាម័យសាធារណៈល្អ
- **លើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ** : បង្កើនការយល់ដឹង និងដោះស្រាយបញ្ហាយេនឌ័រ បង្កើនភាពអង់អាចដល់ស្ត្រីនៅថ្នាក់ធ្វើសេចក្ដីសម្រេចចិត្ត និងកិច្ចការពារកុមារ ដើម្បីជួយកាត់បន្ថយការរើសអើង ផ្នត់គំនិតជាអវិជ្ជមានលើស្ត្រី និងលើកកម្ពស់ការអនុវត្តសិទ្ធិស្មើភាពរវាងបុរស និងស្ត្រីនៅក្នុងការធ្វើសេចក្ដីសម្រេច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

## ២. លក្ខណវិនិច្ឆ័យក្នុងការកំណត់អ្នកទទួលផលផ្ទាល់

មេឃុំ ចៅសង្កាត់ និង គ.ក.ន.ក ត្រូវកំណត់អ្នកទទួលផលផ្ទាល់ ដោយផ្អែកតាមលក្ខណវិនិច្ឆ័យដូចខាងក្រោម :

- **ការលើកកម្ពស់សុខភាពមាតា** : សកម្មភាពនេះផ្ដោតសំខាន់ទៅលើស្ត្រី ពិសេសស្ត្រីមានផ្ទៃពោះដែលមានជីវភាពក្រីក្រខ្លាំង ហើយដែលរស់នៅក្នុងភូមិឆ្ងាយដាច់ស្រយាល ឬភូមិដែលពុំមានសេវាសុខភាពគ្រប់គ្រាន់
- **ការបង្កើនការចូលរៀននៅមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍** : សកម្មភាពនេះផ្ដោតទៅលើភូមិដែលពុំមានឬនៅឆ្ងាយពីសាលាមត្តេយ្យសិក្សារដ្ឋ ហើយកុមារអាយុ៣-៥ឆ្នាំមានចំនួនច្រើន ភូមិដែលនៅដាច់ស្រយាល ឬតំបន់ដែលមានជនជាតិដើមភាគតិច
- **ការលើកកម្ពស់អនាម័យ** : សកម្មភាពនេះផ្ដោតទៅលើភូមិ ឬតំបន់ដែលប្រជាពលរដ្ឋមានការយល់ដឹងទាបអំពីអនាម័យផ្ទាល់ខ្លួន អនាម័យសាធារណៈ ការប្រើប្រាស់ទឹកស្អាត ការប្រើប្រាស់បង្គន់អនាម័យ ការរស់នៅស្អាត ភូមិដែលខ្វះអនាម័យខ្លាំង និងប្រជាពលរដ្ឋមានជីវភាពក្រីក្រ
- **ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ** : សកម្មភាពនេះផ្ដោតទៅលើការអប់រំគោលគំនិតយេនឌ័រ ការដោះស្រាយបញ្ហាយេនឌ័រ ការគាំទ្រដល់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ក្រុមគោលដៅជាស្ត្រី កុមារ ស្ត្រីស្ថិតក្នុងគ្រួសារដែលមានជីវភាពក្រីក្រ ជនងាយរងគ្រោះ និងថ្នាក់ដឹកនាំភូមិជាស្ត្រី។

## ៣. ការរៀបចំផែនការសកម្មភាព និងថវិកា

មេឃុំ ចៅសង្កាត់ និង គ.ក.ន.ក ត្រូវរៀបចំកិច្ចប្រជុំពិនិត្យមើលកម្មវិធីវិនិយោគឃុំ សង្កាត់ និងប្រើប្រាស់ទិន្នន័យសៀវភៅស្ថានភាពឃុំ សង្កាត់ សៀវភៅទិន្នន័យភូមិ និងទិន្នន័យផ្សេងៗទៀត ដើម្បីវិភាគទិន្នន័យក្នុងការកំណត់សកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារសម្រាប់រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ(**ទម្រង់ទី១**) និងផែនការថវិកាប្រចាំឆ្នាំ (**ទម្រង់ទី២**)។ ការវិភាគទិន្នន័យអាចប្រើប្រាស់ឧបករណ៍វិភាគទិន្នន័យដូចជា ផែនទីសេវាសង្គម តារាងពិន្ទុគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ល។ ផែនការសកម្មភាព និងផែនការថវិកានេះត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត ហើយត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់។ នៅដើមត្រីមាសនីមួយៗ គ.ក.ន.ក ត្រូវរៀបចំផែនការសកម្មភាពប្រចាំត្រីមាសរបស់ខ្លួន (**ទម្រង់ទី៣**)។

## ៤. ការអនុវត្តសកម្មភាព

គ.ក.ន.ក អាចអនុវត្តមុខងារអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ តាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម :

### ៤.១. សកម្មភាពលើកកម្ពស់សុខភាពមាតា

ក្នុងការលើកកម្ពស់សុខភាពមាតា គ.ក.ន.ក ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម :

**ក. ពង្រឹងបណ្តាញភ្នាក់ងារសុខភាពភូមិ**

- ជំរុញភ្នាក់ងារសុខភាពភូមិក្នុងការប្រមូលព័ត៌មានចាំបាច់នានាពាក់ព័ន្ធនឹងបញ្ហាសុខភាពមាតា និងទារក
- រាយការណ៍អំពីស្ថានភាពសេវាសុខភាពនៅមណ្ឌលសុខភាព និងបញ្ហាផ្សេងៗទាក់ទងនឹងសុខភាពមាតា និងទារក ជូនគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និង គ.ក.ន.ក
- រៀបចំកិច្ចប្រជុំជាមួយភ្នាក់ងារសុខភាពភូមិក្នុងឃុំ សង្កាត់ ដើម្បីកំណត់អំពីស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេ និងជាជនងាយរងគ្រោះ ដើម្បីទទួលបានការគាំទ្រមធ្យោបាយធ្វើដំណើរ និងឬអាហារក្នុងអំឡុងពេលសម្រាលកូននៅមណ្ឌលសុខភាព
- ជំរុញ និងលើកទឹកចិត្តភ្នាក់ងារសុខភាពភូមិក្នុងការចលនាប្រជាពលរដ្ឋឱ្យមកទទួលសេវាពិនិត្យផ្ទៃពោះមុនសម្រាលកូន និងពិនិត្យសុខភាពក្រោយពេលសម្រាលកូននៅមណ្ឌលសុខភាព បញ្ជូនកូនមកចាក់វ៉ាក់សាំងការពារ និងទទួលសេវាព្យាបាលជំងឺនៅមណ្ឌលសុខភាព។

**ខ. អប់រំ និងផ្សព្វផ្សាយទាក់ទងនឹងការលើកកម្ពស់សុខភាពមាតា**

- ការយល់ដឹងអំពីការថែទាំសុខភាពមាតា និងទារកសម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីជាមាតា
- ការយល់ដឹងអំពីសារសំខាន់នៃផែនការគ្រួសារ
- ការយល់ដឹងអំពីសារសំខាន់នៃការពិនិត្យផ្ទៃពោះមុន ពិនិត្យសុខភាពក្រោយសម្រាល និងមកសម្រាលកូននៅមណ្ឌលសុខភាព
- ការយល់ដឹងអំពីសារសំខាន់នៃសុខភាពផ្លូវភេទ សុខភាពបន្តពូជ និងការប្រើប្រាស់មធ្យោបាយពន្យារកំណើត
- ការយល់ដឹងអំពីសារសំខាន់នៃការចាក់វ៉ាក់សាំងការពារ ការផ្តល់ជីវជាតិបន្ថែម និងទទួលសេវាព្យាបាលជំងឺនៅមណ្ឌលសុខភាព។

**គ. គាំទ្រមធ្យោបាយធ្វើដំណើរ និងឬអាហារសម្រាប់សម្រាលកូននៅមណ្ឌលសុខភាព**

- ស្រង់បញ្ជីស្ត្រីមានផ្ទៃពោះ ដើម្បីកំណត់អំពីស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេសម្រាប់ទទួលបានការគាំទ្រ
- សំណើសុំជាលាយលក្ខណ៍អក្សរ (ទម្រង់ទី៤)
- ប្រជុំរបស់ គ.ក.ន.ក ដើម្បីពិនិត្យ និងសម្រេច។ ក្នុងករណីសង្គ្រោះបន្ទាន់ មេឃុំ ចៅសង្កាត់អាចសម្រេចផ្តល់ការគាំទ្រនេះដល់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេ ហើយបន្ទាប់មកត្រូវរាយការណ៍អំពីករណីនេះ ក្នុងកិច្ចប្រជុំ គ.ក.ន.ក

- ផ្ដល់ព័ត៌មានដល់អ្នកស្នើសុំអំពីការសម្រេចរបស់ គ.ក.ន.ក
- ផ្ដល់ថវិកាសម្រាប់មធ្យោបាយធ្វើដំណើរឬអាហារ ឬផ្ដល់ជាអាហារ ឬរៀបចំមធ្យោបាយធ្វើដំណើរ

## ៤.២. សកម្មភាពបង្កើត និងដំណើរការមត្តេយ្យសិក្សាសហគមន៍

ក្នុងការរៀបចំបង្កើត និងដំណើរការមត្តេយ្យសិក្សាសហគមន៍ គ.ក.ន.ក ត្រូវអនុវត្តតាមជំហានដូចខាងក្រោម :

### ក. កំណត់ និងជ្រើសរើសទីតាំងសម្រាប់រៀបចំបង្កើតមត្តេយ្យសិក្សាសហគមន៍

- ពិនិត្យទិន្នន័យភូមិ ទិន្នន័យស្ថានភាពឃុំ សង្កាត់ និងទិន្នន័យដទៃទៀត ដើម្បីកំណត់ចំនួនកុមារអាយុ ៣-៥ឆ្នាំតាមភូមិនីមួយៗ
- រៀបចំប្រជុំ គ.ក.ន.ក ដើម្បីជ្រើសរើសភូមិ និងកំណត់ទីតាំងសម្រាប់រៀបចំមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍
- ចុះពិនិត្យ និងវាយតម្លៃទីតាំងសម្រាប់រៀបចំមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងពិភាក្សាជាមួយម្ចាស់ទីតាំង ដើម្បីព្រមព្រៀងលើការផ្ដល់ទីតាំង
- ប្រជុំជាមួយមាតាបិតាកុមារ ដើម្បីពិគ្រោះយោបល់អំពីដំណើរការមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងបញ្ជូនកូនទៅរៀន

**មណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍ត្រូវ :**

- ស្ថិតនៅភូមិដែលភាគច្រើនមានកុមារអាយុពី៣-៥ឆ្នាំរស់នៅ និងងាយស្រួលធ្វើដំណើរទៅមក
- មានទំហំទីធ្លាសមស្របសម្រាប់កុមារលេងកំសាន្ត មានម្លប់ មានអនាម័យល្អ មានសុវត្ថិភាព និងមានបង្គន់អនាម័យ
- ទំហំមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍សមស្រប (យ៉ាងតិចមានទំហំ៥ម៉ែត្រគុណនឹង៦ម៉ែត្រ ឬធំជាងនេះ) និងមានសុវត្ថិភាព។ បច្ចុប្បន្ននេះ មណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍អាចរៀបចំនៅសាលាឆទាន វត្តអារាម ស្នាក់ការភូមិ ផ្ទះប្រជាពលរដ្ឋ មណ្ឌលអប់រំសហគមន៍ និងសាលាបឋមសិក្សា ។ល។
- មណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍នីមួយៗគួរមានកុមារ២០នាក់។ ការចូលរៀនត្រូវផ្ដល់អាទិភាពខ្ពស់ចំពោះកុមារដែលមានអាយុ៥ឆ្នាំ បន្ទាប់មកកុមារដែលមានអាយុ៤ឆ្នាំ និងបន្ទាប់មកទៀតកុមារដែលមានអាយុ៣ឆ្នាំ។

### ខ. ផ្សព្វផ្សាយ និងចលនាមាតាបិតាឱ្យបញ្ជូនកូនទៅរៀននៅមត្តេយ្យសិក្សាសហគមន៍

- មេភូមិចុះផ្សព្វផ្សាយដល់គ្រួសារដែលមានកុមារអាយុ៣-៥ឆ្នាំក្នុងភូមិរបស់ខ្លួន ឱ្យបញ្ជូនកូនទៅចូលរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍
- បិទផ្សាយព័ត៌មានអំពីមត្តេយ្យសិក្សាសហគមន៍នៅក្ដារព័ត៌មានឃុំ សង្កាត់ និងទីសាធារណៈក្នុងភូមិ
- ស្រង់ និងចុះឈ្មោះកុមារចូលរៀនមត្តេយ្យសិក្សាសហគមន៍។

គ. ជ្រើសរើស និងធ្វើកិច្ចសន្យាជាមួយគ្រូមត្តេយ្យសិក្សាសហគមន៍

- មេឃុំ ចៅសង្កាត់រៀបចំសេចក្តីបរិយាយមុខងារ លក្ខណសម្បត្តិ រយៈពេលនៃការបំពេញការងារ ចំនួនម៉ោងបង្រៀនក្នុងមួយថ្ងៃ ចំនួនប្រាក់ឧបត្ថម្ភប្រចាំខែ និងសមាសភាពគណៈកម្មការជ្រើសរើស ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងសម្រេច
- បន្ទាប់ពីបានទទួលការឯកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវរៀបចំសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ និងសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍។ សេចក្តីជូនដំណឹងនេះត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដូចជាបិទផ្សាយនៅក្តារព័ត៌មានឃុំ សង្កាត់ ទីសាធារណៈតាមភូមិ ឬតាមមធ្យោបាយផ្សេងទៀតដែលឃុំ សង្កាត់អាចធ្វើបាន
- ដំណើរការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍អាចធ្វើឡើងតាមនីតិវិធីជ្រើសរើស តាមរយៈប្រវត្តិរូបសង្ខេប ឬនីតិវិធីប្រលងជ្រើសរើស
- គណៈកម្មការជ្រើសរើសត្រូវអនុវត្តដំណើរការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ ទៅតាមនីតិវិធីនៃការជ្រើសរើសបុគ្គលិកដែលបានកំណត់នៅក្នុងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (ខែវិច្ឆិកា ឆ្នាំ២០០៥)
- មេឃុំ ចៅសង្កាត់ត្រូវរៀបចំកិច្ចសន្យាជាមួយគ្រូមត្តេយ្យសិក្សាសហគមន៍ (**ទម្រង់ទី៥**)។

គ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម :

- ជាអ្នកមានចំណេះដឹងទូទៅយ៉ាងតិចបំផុតរៀនចប់បឋមសិក្សា ឬសមមូល
- ជាអ្នកចង់ទទួលនូវការបណ្តុះបណ្តាលលើជំនាញបង្រៀនមត្តេយ្យសិក្សាសហគមន៍
- មានចំណង់ចំណូលចិត្តក្នុងការបង្រៀន និងការជួយកុមារ
- ជាទូទៅជាស្ត្រី ឬបុរសដែលរស់នៅក្នុងភូមិ ឃុំ សង្កាត់នោះ
- ជាអ្នកអំណត់អត់ធ្មត់
- មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។

ឃ. បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ដោយមន្ទីរអប់រំ យុវជន និងកីឡា

- អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី ខេត្ត ឬទីចាត់ការទទួលបន្ទុកការងារនេះ ត្រូវសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីរៀបចំបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសមត្តេយ្យសិក្សាសហគមន៍ និងផ្តល់សម្ភារឧបទេស និងឧបករណ៍សម្រាប់ការបង្រៀនដល់គ្រូមត្តេយ្យសិក្សាសហគមន៍។

ង. ការគ្រប់គ្រង និងការបង្រៀននៅមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍

- គ្រូមត្តេយ្យសិក្សាសហគមន៍ ត្រូវបង្រៀនកុមារនៅមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍យ៉ាងតិច **រយៈពេល២ម៉ោងក្នុង១ថ្ងៃ ១សប្តាហ៍៥ថ្ងៃ** (ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ) **ស្មើនឹង០៩ខែក្នុង១ឆ្នាំ** (ចាប់ពីខែតុលាដល់ខែកក្កដា)។ ការឈប់សម្រាកផ្លូវការត្រូវអនុវត្តតាមប្រតិទិនរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា
- គ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវជួយអប់រំផ្សព្វផ្សាយដល់មាតាបិតា ឬអាណាព្យាបាលកុមារអំពីមត្តេយ្យសិក្សាសហគមន៍
- គ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវគ្រប់គ្រង និងថែទាំសម្ភារឧបទេស និងឧបករណ៍របស់មណ្ឌល/សាលាមត្តេយ្យសិក្សាសហគមន៍
- គ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវរៀបចំរបាយការណ៍តាមដានវត្តមានសិស្ស (**ទម្រង់ទី៦**) និងរបាយការណ៍ប្រចាំខែស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ (**ទម្រង់ទី៧**)
- ការបើកប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវធ្វើឡើងតាមការកំណត់នៅក្នុងកិច្ចសន្យា
- តាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការអនុវត្តមត្តេយ្យសិក្សាសហគមន៍
- រៀបចំប្រជុំជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស ដើម្បីផ្តល់យោបល់អំពីដំណើរការមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍។

## ៤.៣. សកម្មភាពលើកកម្ពស់អនាម័យ

ក្នុងការលើកកម្ពស់អនាម័យ គ.ក.ន.ក ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម :

ក. ពង្រឹងបណ្តាញការងារអនាម័យសហគមន៍

- សហការជាមួយការិយាល័យអភិវឌ្ឍន៍ជនបទក្រុង ស្រុក ខណ្ឌ ក្នុងការជ្រើសរើសអ្នកសម្របសម្រួលអនាម័យភូមិ
- ជំរុញ និងលើកទឹកចិត្តដល់អ្នកសម្របសម្រួលអនាម័យភូមិ ក្នុងការប្រមូលព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពអនាម័យនៅតាមគ្រួសារ អនាម័យភូមិ ពិសេសការប្រើប្រាស់បង្គន់អនាម័យ ការហូបនិងទុកដាក់ទឹកប្រកបដោយសុវត្ថិភាព
- រៀបចំកិច្ចប្រជុំជាមួយអ្នកសម្របសម្រួលអនាម័យភូមិ និងការិយាល័យអភិវឌ្ឍន៍ជនបទក្រុង ស្រុក ខណ្ឌ ដើម្បីស្វែងរកតម្រូវការនៃការគាំទ្រ និងរៀបចំសកម្មភាពសហគមន៍ក្នុងការលើកកម្ពស់អនាម័យ
- ជំរុញ និងលើកទឹកចិត្តដល់អ្នកសម្របសម្រួលអនាម័យភូមិ ក្នុងការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ ដើម្បីឈានទៅបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល។

ខ. អប់រំ និងផ្សព្វផ្សាយទាក់ទងនឹងការលើកកម្ពស់អនាម័យនៅមូលដ្ឋាន

- ការយល់ដឹងអំពីសារសំខាន់នៃទម្លាប់ល្អនៃអនាម័យផ្ទាល់ខ្លួន និងអនាម័យសាធារណៈ
- ការយល់ដឹងអំពីសារសំខាន់នៃការប្រើប្រាស់ទឹកសុវត្ថិភាព
- ការយល់ដឹងអំពីសារសំខាន់នៃការប្រើប្រាស់បង្គន់អនាម័យ
- រៀបចំទិវាអនាម័យសំខាន់ៗប្រចាំឆ្នាំ ដូចជា ទិវាទឹកពិភពលោក ថ្ងៃទី២២ ខែមីនា ទិវាពិភពលោកលាងសម្អាតដៃ ថ្ងៃទី១៥ ខែតុលា និងទិវាអនាម័យជាតិថ្ងៃ១៣ ខែវិច្ឆិកា ។

គ. ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ ឬធុងចម្រោះទឹកស្អាតដល់គ្រួសារក្រីក្រ និងសាលារៀន

- សំណើសុំជាលាយលក្ខណ៍អក្សរ (ទម្រង់ទី៤)
- ប្រជុំរបស់ គ.ក.ន.ក ដើម្បីពិនិត្យ និងសម្រេច
- ផ្តល់ព័ត៌មានដល់អ្នកស្នើសុំអំពីការសម្រេចរបស់ គ.ក.ន.ក
- ស្វែងរកអ្នកផ្គត់ផ្គង់សម្ភារៈបង្គន់អនាម័យ ឬធុងចម្រោះទឹកស្អាត
- ការប្រគល់ និងទទួលសម្ភារៈបង្គន់អនាម័យ ឬធុងចម្រោះទឹកស្អាតដល់អ្នកស្នើសុំ ។

## ៤.៤. សកម្មភាពលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ

ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ គ.ក.ន.ក ត្រូវអនុវត្តសកម្មភាពដូចខាងក្រោម :

ក. ពង្រឹងបណ្តាញការងារយេនឌ័រ និងកិច្ចការពារកុមារនៅមូលដ្ឋាន

- ប្រជុំផ្លាស់ប្តូរយោបល់ជាមួយស្ត្រីនៅតាមភូមិ ដើម្បីស្វែងយល់អំពីតម្រូវការ និងបញ្ហាប្រឈមរបស់ស្ត្រី និងកុមារ
- លើកទឹកចិត្តអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការចលនាប្រជាពលរដ្ឋឱ្យទៅចុះបញ្ជីកំណើត ចុះឈ្មោះចូលរៀន និងទទួលសេវាថែទាំសុខភាពនៅមណ្ឌលសុខភាព
- រៀបចំវេទិកាជាមួយស្ត្រីជាថ្នាក់ដឹកនាំភូមិ សហគមន៍ និងប្រជាពលរដ្ឋ ដើម្បីពិភាក្សាលើបញ្ហារបស់ស្ត្រី និងកុមារក្នុងការរកវិធានការដោះស្រាយសមស្រប
- ជំរុញ និងលើកទឹកចិត្ត គ.ក.ន.ក ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដើម្បីធានាថា បញ្ហាស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ និងបញ្ហាយេនឌ័រ ត្រូវបានបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

ខ. អប់រំ និងផ្សព្វផ្សាយទាក់ទងនឹងការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ

- ការយល់ដឹងអំពីគោលគំនិត និងបញ្ហាយេនឌ័រ
- ការយល់ដឹងអំពីសិទ្ធិស្ត្រីនិងកុមារ និងកាត់បន្ថយការរើសអើងទៅលើស្ត្រីក្នុងគ្រួសារ និងសហគមន៍
- ការយល់ដឹងអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

- ការយល់ដឹងអំពីកិច្ចការពារកុមារ និងកេងប្រវ័ញ្ចពលកម្មកុមារ
- ការយល់ដឹងអំពីការទប់ស្កាត់ការរំលោភផ្លូវភេទ
- ការយល់ដឹងអំពីការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ
- ការយល់ដឹងអំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន និងទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍
- ការយល់ដឹងអំពីការឱ្យតម្លៃការអប់រំដល់កូនស្រី
- ការយល់ដឹងអំពីការស្វែងរកការគាំទ្រមតិ (ការតស៊ូមតិ)
- ការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព
- ផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងទៅលើប្រធានបទនានាទាក់ទងនឹងស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ ។

**គ. គាំទ្រមធ្យោបាយធ្វើដំណើរដល់ស្ត្រី និងកុមាររងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារទៅកាន់កន្លែងផ្តល់សេវាសង្គ្រោះ**

- សំណើសុំជាលាយលក្ខណ៍អក្សរ (**ទម្រង់ទី៤**)
- មេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេច ។ បន្ទាប់មក មេឃុំ ចៅសង្កាត់រាយការណ៍ជូនកិច្ចប្រជុំ គ.ក.ន.ក
- បញ្ជូនជនរងគ្រោះទៅកាន់សេវាសង្គ្រោះ
- ផ្តល់ជាថវិកា ឬផ្តល់មធ្យោបាយធ្វើដំណើរ ។

## ៥. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវជួយមេឃុំ ចៅសង្កាត់ និង គ.ក.ន.ក ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារដែលមាននៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃអាចធ្វើឡើងតាមរយៈសកម្មភាពដូចខាងក្រោម :

- ចុះតាមដានត្រួតពិនិត្យដំណើរការអនុវត្តសកម្មភាព និងលទ្ធផលការងារ
- រៀបចំរបាយការណ៍រីកចម្រើនស្តីពីការអនុវត្តសកម្មភាព (**ទម្រង់ទី៨**) និងរបាយការណ៍រីកចម្រើនស្តីពីការអនុវត្តថវិកា (**ទម្រង់ទី៩**) ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រាយការណ៍អំពីភាពរីកចម្រើននៃការអនុវត្តសកម្មភាព និងថវិកាជូន គ.ក.ន.ក និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដោះស្រាយបញ្ហានានា និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការវាយតម្លៃផលប៉ះពាល់នៃការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់ ។

## ៦. ការទូទាត់ និងកិច្ចបញ្ជីកាគណនេយ្យ

ចំពោះមូលនិធិដែលទទួលបានពី គ.ជ.អ.ប មេឃុំ ចៅសង្កាត់ត្រូវអនុវត្តនីតិវិធីទូទាត់ និងចុះកិច្ចបញ្ជីកាគណនេយ្យទៅតាមនីតិវិធីដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។ ចំណែកឯមូលនិធិដែលទទួលបានពីដៃគូអភិវឌ្ឍន៍នានា មេឃុំ ចៅសង្កាត់ត្រូវអនុវត្តនីតិវិធីទូទាត់ និងចុះកិច្ចបញ្ជីកាគណនេយ្យទៅតាមនីតិវិធីដែលបានព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍នីមួយៗនោះ។

## ៧. យន្តការគាំទ្រការអនុវត្ត

### ៧.១. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- សម្របសម្រួលជាមួយមន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធ ដើម្បីជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ
- ស្វែងរកការគាំទ្រពីក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការផ្សេងៗទៀតរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមដោះស្រាយបញ្ហានានាទាក់ទងនឹងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ។

### ៧.២. អង្គភាពរដ្ឋបាលមូលដ្ឋាន (ឬទីចាត់ការទទួលការងារនេះនៅក្នុងរចនាសម្ព័ន្ធថ្មី)

អង្គភាពរដ្ឋបាលមូលដ្ឋាន ឬទីចាត់ការទទួលបន្ទុកមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ផ្សព្វផ្សាយ និងបណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានា
- ជំរុញ និងគាំទ្រដល់ឃុំ សង្កាត់ក្នុងការផ្សព្វផ្សាយព័ត៌មាន និងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅក្នុងឃុំ សង្កាត់របស់ខ្លួន
- សម្របសម្រួលជាមួយមន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក
- ជំរុញ គ.ក.ន.ក ក្នុងការលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលឱ្យចូលរួមក្នុងកិច្ចប្រជុំប្រចាំត្រីមាសរបស់ គ.ក.ន.ក នៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- ណែនាំ និងជំរុញឃុំ សង្កាត់ ក្នុងការចូលរួមប្រជុំគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងគណៈកម្មការទ្រទ្រង់សាលារៀន

- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គម ក្នុងការលើកកម្ពស់សុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំស្តីពីការរីកចម្រើននៃការអនុវត្តសកម្មភាព និងឱកាសសម្រាប់រាជធានី ខេត្តរបស់ខ្លួន ជូនគណៈអភិបាលរាជធានី ខេត្ត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមការងារសេវាសង្គមថ្នាក់ជាតិនៃលេខាធិការដ្ឋាន គ.ជ.អ.ប ។

## ៧.៣. មន្ទីរសុខាភិបាល

មន្ទីរសុខាភិបាលមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ពង្រឹង និងជំរុញការិយាល័យស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា និងទារក
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងប្រជាពលរដ្ឋ ទាក់ទងនឹងការលើកកម្ពស់សុខភាពមាតា និងទារក
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា និងទារក
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ក្នុងការលើកកម្ពស់សុខភាពមាតា និងទារក
- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការពង្រឹងបណ្តាញការងារសុខភាពភូមិ
- បង្កើន និងពង្រឹងគុណភាពសេវាសុខភាពមាតា និងទារកនៅមូលដ្ឋាន
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា និងទារក
- ណែនាំ និងពង្រឹងមណ្ឌលសុខភាពក្នុងការចូលរួមក្នុងកិច្ចប្រជុំ គ.ក.ន.ក និងជំរុញកិច្ចសហប្រតិបត្តិការរវាងគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និង គ.ក.ន.ក ។

## ៧.៤. មន្ទីរអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ពង្រឹង និងជំរុញការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងនាយកសាលាបឋមសិក្សាក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍
- បណ្តុះបណ្តាល ផ្តល់ឯកសារ និងសម្ភារៈសិក្សាដល់គ្រូមត្តេយ្យសិក្សាសហគមន៍
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ទាក់ទងនឹងការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍
- ចូលរួមដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍

- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍
- តាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការមត្តេយ្យសិក្សាសហគមន៍
- ណែនាំ និងពង្រឹងនាយកសាលាក្នុងការចូលរួមក្នុងកិច្ចប្រជុំ គ.ក.ន.ក និងជំរុញកិច្ចសហប្រតិបត្តិការរវាងនាយកសាលាបឋមសិក្សា និង គ.ក.ន.ក។

## ៧.៥. មន្ទីរអភិវឌ្ឍន៍ជនបទ

មន្ទីរអភិវឌ្ឍន៍ជនបទមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ពង្រឹង និងជំរុញការិយាល័យអភិវឌ្ឍន៍ជនបទ ក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីអនុវត្តសកម្មភាពលើកកម្ពស់អនាម័យនៅមូលដ្ឋាន
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងប្រជាពលរដ្ឋ ទាក់ទងនឹងការលើកកម្ពស់អនាម័យនៅមូលដ្ឋាន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពលើកកម្ពស់អនាម័យនៅមូលដ្ឋាន
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការលើកកម្ពស់អនាម័យនៅមូលដ្ឋាន
- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការពង្រឹងបណ្តាញការងារអនាម័យនៅមូលដ្ឋាន
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់អនាម័យនៅមូលដ្ឋាន។

## ៧.៦. មន្ទីរកិច្ចការនារី

មន្ទីរកិច្ចការនារីមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ពង្រឹង និងជំរុញការិយាល័យកិច្ចការនារីក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីអនុវត្តសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងប្រជាពលរដ្ឋទាក់ទងនឹងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី
- ពង្រឹងបណ្តាញការងារយេនឌ័រនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីជួយគាំទ្រសកម្មភាពលើកកម្ពស់សមភាពយេនឌ័រនៅថ្នាក់ឃុំ សង្កាត់
- ជួយ គ.ក.ន.ក ក្នុងការពង្រឹងបណ្តាញការងារយេនឌ័រនៅឃុំ សង្កាត់
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។

### ៧.៧. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ពង្រឹង និងជំរុញការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ដើម្បីអនុវត្តសកម្មភាពការពារកុមារ និងជនងាយរងគ្រោះ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងប្រជាពលរដ្ឋទាក់ទងនឹងកិច្ចការពារកុមារ និងជនងាយរងគ្រោះ
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពការពារកុមារ និងជនងាយរងគ្រោះ
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ក.ន.ក ក្នុងការលើកកម្ពស់កិច្ចការពារកុមារ និងជនងាយរងគ្រោះ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពលើកកម្ពស់កិច្ចការពារកុមារ និងជនងាយរងគ្រោះ ។

ទទួលបានសេចក្តីណែនាំនេះ ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធត្រូវអនុវត្តសេចក្តីណែនាំឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ៚

រាជធានីភ្នំពេញ, ថ្ងៃទី.១៤... ខែ.កក្កដា... ឆ្នាំ២០១០

**ជ. គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**ប្រធាន**

ស ខេង

**ចម្លងជូន**

- គ.ជ.អ.ប
- ក្រសួងសុខាភិបាល
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងកិច្ចការនារី
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  "ដើម្បីសហការអនុវត្ត"
- អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ

ទម្រង់ទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :.......................
ក្រុង ស្រុក ខណ្ឌ :....................
ឃុំ សង្កាត់ :.........................

## ផែនការសកម្មភាពប្រចាំឆ្នាំ..........

## ស្តីពីការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១ | ការលើកកម្ពស់សុខភាពមាតា | | | | | | | | | | | | | | | | | |
| ១.១. | | | | | | | | | | | | | | | | | | |
| ១.២. | | | | | | | | | | | | | | | | | | |
| ២ | ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ | | | | | | | | | | | | | | | | | |
| ២.១. | | | | | | | | | | | | | | | | | | |
| ២.២. | | | | | | | | | | | | | | | | | | |
| ៣ | ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន | | | | | | | | | | | | | | | | | |
| ៣.១. | | | | | | | | | | | | | | | | | | |
| ៣.២. | | | | | | | | | | | | | | | | | | |
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | | | | | | | | | | | | | | | | | |
| ៤.១. | | | | | | | | | | | | | | | | | | |
| ៤.២. | | | | | | | | | | | | | | | | | | |
| ៥ | ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក | | | | | | | | | | | | | | | | | |
| ៥.១. | | | | | | | | | | | | | | | | | | |
| ៥.២. | | | | | | | | | | | | | | | | | | |

ថ្ងៃទី...... ខែ.......... ឆ្នាំ......
អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

ថ្ងៃទី...... ខែ.......... ឆ្នាំ......
មេឃុំ ចៅសង្កាត់

**ឧបសម្ព័ន្ធ**

ទម្រង់ទី២

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :..........................

ក្រុង ស្រុក ខណ្ឌ :..........................

ឃុំ សង្កាត់ :..........................

**ផែនការថវិកាប្រចាំឆ្នាំ..........**

**សម្រាប់ការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ**

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប |
|---|---|---|---|---|---|
| ១ | **ការលើកកម្ពស់សុខភាពមាតា និងទារក** | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | - |
| ២ | **មត្តេយ្យសិក្សាសហគមន៍** | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | - |
| ៣ | **ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន** | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | - |
| ៤ | **ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ** | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | - |
| ៥ | **កិច្ចដំណើរការ និងការប្រជុំរបស់ គ.ក.ន.ក** | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | - |
| **សរុបរួម** | | | | | - |

ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**ស្មៀនឃុំ សង្កាត់**

ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**មេឃុំ ចៅសង្កាត់**

**ឧបសម្ព័ន្ធ**

ឧម្រង់ទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :......................

ក្រុង ស្រុក ខណ្ឌ :....................

ឃុំ សង្កាត់ :........................

## ផែនការសកម្មភាពប្រចាំត្រីមាសទី...... ឆ្នាំ..........

## ស្តីពីការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | មេសា | | | | ឧសភា | | | | មិថុនា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| ១ | ការលើកកម្ពស់សុខភាពមាតា | | | | | | | | | | | | | | | | | |
| ១.១. | | | | | | | | | | | | | | | | | | |
| ១.២. | | | | | | | | | | | | | | | | | | |
| ២ | ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ | | | | | | | | | | | | | | | | | |
| ២.១. | | | | | | | | | | | | | | | | | | |
| ២.២. | | | | | | | | | | | | | | | | | | |
| ៣ | ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន | | | | | | | | | | | | | | | | | |
| ៣.១. | | | | | | | | | | | | | | | | | | |
| ៣.២. | | | | | | | | | | | | | | | | | | |
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | | | | | | | | | | | | | | | | | |
| ៤.១. | | | | | | | | | | | | | | | | | | |
| ៤.២. | | | | | | | | | | | | | | | | | | |
| ៥ | ការប្រជុំ និងតាមដានត្រួតពិនិត្យរបស់ គ.ក.ន.ក | | | | | | | | | | | | | | | | | |
| ៥.១. | | | | | | | | | | | | | | | | | | |
| ៥.២. | | | | | | | | | | | | | | | | | | |

ថ្ងៃទី..... ខែ......... ឆ្នាំ......

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ**

ថ្ងៃទី..... ខែ......... ឆ្នាំ......

**មេឃុំ ចៅសង្កាត់**

ឧបសម្ព័ន្ធ
ទម្រង់ទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ....................................... ភេទ............ សញ្ជាតិ............. ឆ្នាំកំណើត.................
អត្តសញ្ញាណប័ណ្ណសញ្ជាតិលេខ.................................... មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ............... ផ្លូវលេខ.............
ឃុំ សង្កាត់................................ ក្រុង ស្រុក ខណ្ឌ................................ រាជធានី ខេត្ត................................។

**គោរពជូន**

**លោក លោកស្រីមេឃុំ ចៅសង្កាត់.........................**

**កម្មវត្ថុ :** សំណើសុំ..........................................................................................................................
..........................................................................................................................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំសូមជម្រាបជូនលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាជ្រាបថា ដោយសារគ្រួសាររបស់ខ្ញុំបាទ នាងខ្ញុំមានជីវភាពខ្វះខាត និងពុំមានថវិកាសម្រាប់...........................
..........................................................................................................................
...........................................................................................។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់មេត្តាពិនិត្យ និងផ្តល់ការគាំទ្រដល់ខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។

សូមលោក លោកស្រីមេឃុំ ចៅសង្កាត់មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំបាទ នាងខ្ញុំ ។

ថ្ងៃទី.......... ខែ................. ឆ្នាំ............

**អ្នកស្នើសុំ**

ឧបសម្ព័ន្ធ

ឧម្រង់ទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :.........................
ក្រុង ស្រុក ខណ្ឌ :.....................
ឃុំ សង្កាត់ :.............................
លេខ :....................

## កិច្ចសន្យាផ្ដល់សេវាបង្រៀនមត្តេយ្យសិក្សាសហគមន៍

កិច្ចសន្យានេះធ្វើឡើងនៅថ្ងៃទី........... ខែ................ ឆ្នាំ........... រវាង..........*(ឈ្មោះឃុំ សង្កាត់)*........ នៃក្រុង ស្រុក ខណ្ឌ.............................. រាជធានី ខេត្ត................................. ហៅកាត់ថា "ឃុំ សង្កាត់" និង .............*(ឈ្មោះគ្រូមត្តេយ្យ)*.............. ដែលមានអាសយដ្ឋាន.................*(ចុះអាសយដ្ឋានគ្រូមត្តេយ្យ)*.......... ........................................................ ហៅកាត់ថា "គ្រូមត្តេយ្យ"។

ភាគីទាំងពីរព្រមព្រៀងគ្នាដូចតទៅ :

### ១. លក្ខខណ្ឌការងារ

ក). គ្រូមត្តេយ្យនឹងបំពេញការងារជូនដល់ឃុំ សង្កាត់ ដូចខាងក្រោម :

- ផ្សព្វផ្សាយប្រតិទិនសិក្សាប្រចាំឆ្នាំរបស់មត្តេយ្យសិក្សាសហគមន៍ដល់មាតាបិតាសិស្ស
- សហការជាមួយ គ.ក.ន.ក ក្នុងការអប់រំ ផ្សព្វផ្សាយ និងចលនាមាតាបិតាបញ្ជូនកូនមករៀន
- រៀបចំចុះឈ្មោះកុមារសម្រាប់ការចូលរៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍
- រៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃ សម្រាប់ការបង្រៀន
- បង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ឱ្យបានទៀងទាត់ទៅតាមប្រតិទិន និងពេលវេលាដែលបានឯកភាព
- អនុវត្តវិធីសាស្ត្របង្រៀនទៅការណែនាំរបស់ក្រសួង ឬមន្ទីរអប់រំ យុវជន និងកីឡា
- រៀបចំទុកដាក់សម្ភារៈ និងឧបករណ៍បង្រៀនឱ្យបានត្រឹមត្រូវ និងគង់វង្ស
- ចូលរួមរៀបចំកម្មវិធីមត្តេយ្យសិក្សាសហគមន៍ ការបណ្តុះបណ្តាល និងសិក្ខាសាលា
- តាមដានត្រួតពិនិត្យ និងចុះវត្តមានរបស់សិស្សប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ប្រចាំខែស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍។

ខ). គ្រូមត្តេយ្យនឹងធ្វើការងារក្រោមការគ្រប់គ្រងផ្ទាល់របស់មេឃុំ ចៅសង្កាត់។

គ). គ្រូមត្តេយ្យនឹងបំរើការងារនៅ..........*(ឈ្មោះភូមិនៃទីតាំងសាលាមត្តេយ្យសិក្សាសហគមន៍)*...........។

### ២. រយៈពេលនៃកិច្ចសន្យា

កិច្ចសន្យានេះធ្វើឡើងសម្រាប់រយៈពេល...........ខែ ចាប់ផ្តើមនៅថ្ងៃទី.......... ខែ................ ឆ្នាំ............ ដល់ថ្ងៃទី.......... ខែ................ ឆ្នាំ............។

២៤

ឧបសម្ព័ន្ធ

## ៣. ប្រាក់ឧបត្ថម្ភ

ឃុំ សង្កាត់នឹងបើកជូនគ្រូមត្តេយ្យនូវប្រាក់ឧបត្ថម្ភចំនួន...............................រៀលក្នុងមួយខែ (ជាអក្សរ .........................................................) ។ ការទូទាត់ប្រាក់នឹងត្រូវធ្វើឡើងនៅដំណាច់ខែនីមួយៗ បន្ទាប់ពីគ្រូមត្តេយ្យដាក់ជូនរបាយការណ៍ប្រចាំខែស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងរបាយការណ៍តាមដានវត្តមានសិស្សប្រចាំខែ ។

## ៤. ថិរវេលាធ្វើការ

គ្រូមត្តេយ្យនឹងបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន.........ម៉ោងក្នុង១ថ្ងៃ ៥ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ។ ពេលម៉ោងបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ គឺចាប់ផ្តើមពីម៉ោង..............ដល់ម៉ោង............. ។

## ៥. ការឈប់សម្រាកផ្លូវការ និងការឈប់សំរាកពិសេស

គ្រូមត្តេយ្យមានសិទ្ធិទទួលបាននូវការឈប់សម្រាកផ្លូវការ (បុណ្យជាតិ) តាមប្រតិទិនឈប់សម្រាកជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា ។

គ្រូមត្តេយ្យមានសិទ្ធិទទួលបាននូវការឈប់សម្រាកពិសេស ក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃបុគ្គលិកនោះ ។

ចំពោះគ្រូមត្តេយ្យជាស្ត្រីមានសិទ្ធិឈប់សម្រាកលំហែមាតុភាពរយៈពេល០៣ខែ ដោយទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ ។

## ៦. ការបញ្ចប់កិច្ចសន្យា

ភាគីណាមួយក៏អាចបញ្ចប់កិច្ចសន្យានេះពេលណាក៏បាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតចំនួន៣០ថ្ងៃជាមុន ។

ក្នុងករណីត្រូវបានបណ្តេញចេញពីការងារ ដោយសារការប្រព្រឹត្តខុសឆ្គងធ្ងន់ធ្ងរ កិច្ចសន្យាត្រូវបានបញ្ចប់ដោយចូលជាធរមានភ្លាម ។

## ៧. ការដោះស្រាយជំលោះ

ជម្លោះណាមួយដែលកើតឡើងទាក់ទងនឹងកិច្ចសន្យានេះ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យនិងសម្រេច ។

កិច្ចសន្យានេះត្រូវធ្វើឡើងចំនួន០២ច្បាប់ ហើយត្រូវរក្សាទុកនៅភាគីទាំងពីរ ។

ដើម្បីជាសក្ខីភាពទៅលើកិច្ចសន្យាបម្រើការនេះ ភាគីទាំងពីរបានចុះហត្ថលេខាដូចខាងក្រោម :

**មេឃុំ ចៅសង្កាត់** **គ្រូមត្តេយ្យសិក្សាសហគមន៍**

២៥

25

ឧបសម្ព័ន្ធ

ទម្រង់ទី៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :........................

ក្រុង ស្រុក ខណ្ឌ :......................

ឃុំ សង្កាត់ :...........................

# របាយការណ៍តាមដានវត្តមានសិស្ស

ប្រចាំខែ...................... ឆ្នាំ.......

| ល.រ | ឈ្មោះសិស្ស | ភេទ | | វត្តមានរបស់សិស្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | សរុបតាមសិស្ស | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្រី | ប្រុស | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | វត្តមាន | អវត្តមាន |
| 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 10 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សរុបវត្តមានតាមថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សរុបអវត្តមានតាមថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

កំណត់សម្គាល់ : វត្តមាន ✓ អវត្តមាន X

ថ្ងៃទី...... ខែ.......... ឆ្នាំ......

**គ្រូបង្គោលប្រសិក្សាសហគមន៍**

**ឧបសម្ព័ន្ធ**

ឧម្រង់ទី៧

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :....................

ក្រុង ស្រុក ខណ្ឌ :....................

ឃុំ សង្កាត់ :....................

## របាយការណ៍ស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍

ប្រចាំខែ............. ឆ្នាំ........

| ថ្ងៃ ខែ ឆ្នាំ | មេរៀនដែលបានបង្រៀន | ម៉ោងសិក្សា | | | ចំនួនសិស្ស | |
|---|---|---|---|---|---|---|
| | | ចាប់ផ្តើម | បញ្ចប់ | ចំនួនម៉ោង | វត្តមាន | អវត្តមាន |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

សង្ខេបលទ្ធផលប្រចាំខែ :

ចំនួនថ្ងៃបង្រៀនសរុប :....................................

ចំនួនម៉ោងបង្រៀនសរុប :....................................

ចំនួនភាគរយសិស្សវត្តមាន :....................................

ចំនួនភាគរយសិស្សអវត្តមាន :....................................

ចំនួនមេរៀនដែលបានបង្រៀនសរុប :....................................

ថ្ងៃទី..... ខែ......... ឆ្នាំ......

**គ្រូមត្តេយ្យសិក្សាសហគមន៍**

ថ្ងៃទី..... ខែ......... ឆ្នាំ......

**មេឃុំ ចៅសង្កាត់**

២៧
27

ឧបសម្ព័ន្ធ

ទម្រង់ទី៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :-----------------------

ក្រុង ស្រុក ខណ្ឌ :--------------------

ឃុំ សង្កាត់ :-------------------------

## របាយការណ៍វីកចម្រើនស្តីពីការអនុវត្តសកម្មភាព

## អភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

ប្រចាំ------------------------ ឆ្នាំ-----------

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផល | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | កាលបរិច្ឆេទអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | | |
| ១ | ការលើកកម្ពស់សុខភាពមាតា | | | | | | | |
| ១.១. | | | | | | | | |
| ១.២. | | | | | | | | |
| ២ | ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ | | | | | | | |
| ២.១. | | | | | | | | |
| ២.២. | | | | | | | | |
| ៣ | ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន | | | | | | | |
| ៣.១. | | | | | | | | |
| ៣.២. | | | | | | | | |
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | | | | | | | |
| ៤.១. | | | | | | | | |
| ៤.២. | | | | | | | | |
| ៥ | ការប្រជុំ និងតាមដានត្រួតពិនិត្យរបស់ គ.ក.ន.ក | | | | | | | |
| ៥.១. | | | | | | | | |
| ៥.២. | | | | | | | | |

ថ្ងៃទី----- ខែ--------- ឆ្នាំ------

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ**

ថ្ងៃទី----- ខែ--------- ឆ្នាំ------

**មេឃុំ ចៅសង្កាត់**

ឧបសម្ព័ន្ធ

ទម្រង់ទី៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :.......................

ក្រុង ស្រុក ខណ្ឌ :....................

ឃុំ សង្កាត់ :..........................

# របាយការណ៍រីកចម្រើនស្តីពីការអនុវត្តថវិកា

## សម្រាប់ការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

ប្រចាំ....................... ឆ្នាំ...........

| ល.រ | ការបរិយាយ | ថវិកាគ្រោង | ការចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ក្នុងខែ | បូកយោង | |
| ១ | ការលើកកម្ពស់សុខភាពមាតា | - | - | - | - | - |
| | ការប្រជុំ និងផ្សព្វផ្សាយអំពីសុខភាពមាតា | | | | - | - |
| | ការគាំទ្រស្ត្រីមានផ្ទៃពោះក្នុងការសម្រាលកូននៅមណ្ឌលសុខភាព | | | | - | - |
| ២ | មត្តេយ្យសិក្សាសហគមន៍ | - | - | - | - | - |
| | ការប្រជុំរៀបចំមត្តេយ្យសិក្សាសហគមន៍ | | | | - | - |
| | កិច្ចដំណើរការមត្តេយ្យសហគមន៍ | | | | - | - |
| ៣ | ការលើកកម្ពស់អនាម័យមូលដ្ឋាន | - | - | - | - | - |
| | ការប្រជុំ ការផ្សព្វផ្សាយ និងទិវាអំពីអនាម័យនៅមូលដ្ឋាន | | | | - | - |
| | ការផ្តល់សម្ភារៈសម្រាប់ការងារអនាម័យ | | | | - | - |

| ល.រ | ការបរិយាយ | ថវិកាគ្រោង | ការចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ក្នុងខែ | បូកយោង | |
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | - | - | - | - | - |
| | ការប្រជុំ និងផ្សព្វផ្សាយការងារយេនឌ័រ និងកិច្ចការពារកុមារ | | | | - | - |
| | ការគាំទ្រថ្លៃធ្វើដំណើរជនរងគ្រោះទៅកន្លែងផ្តល់សេវាសង្គ្រោះ | | | | - | - |
| ៥ | កិច្ចដំណើរការ និងការប្រជុំរបស់ គ.ក.ន.ក | - | - | - | - | - |
| | ការរៀបចំប្រជុំ ( អាហារសម្រន់ និងឯកសារ) | | | | - | - |
| | សម្ភារៈការិយាល័យ | | | | - | - |
| | ថ្លៃធ្វើដំណើររបស់ គ.ក.ន.ក | | | | - | - |
| សរុបរួម | | - | - | - | - | - |

២៧

ថ្ងៃទី...... ខែ.......... ឆ្នាំ......

**ស្មៀនឃុំ សង្កាត់**

ថ្ងៃទី...... ខែ.......... ឆ្នាំ......

**មេឃុំ ចៅសង្កាត់**